# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសច្ចានិរន្ដរ៍របស់បងស្រីតេរេសា អេង សានី
# ទីងទំពូន ថ្ងៃទី១២ ខែមករា ឆ្នាំ២០២០
# ឲ្យយើងនៅមុខនៅក្នុងសេរីភាពមកពីព្រះជាម្ចាស់

**អត្ថបទទី១៖ អេសាយ ៤២,១-៤.៦-៧**

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ លោកនេះហើយជាអ្នកបម្រើដែលយើងគាំទ្រ ជាអ្នកដែលយើងបានជ្រើសរើស និងជាទីគាប់ចិត្តរបស់យើង យើងដាក់វិញ្ញាណរបស់យើងលើលោក លោកនឹងបង្ហាញឲ្យប្រជាជាតិទាំងឡាយស្គាល់ការវិនិច្ឆ័យ។ អស ៤២,១

**អត្ថបទទី២៖ កិច្ចការ ១០,៣៤-៣៨**

ក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន អ្នកណាក៏ដោយឲ្យតែគោរពកោតខ្លាចព្រះអង្គ ហើយប្រព្រឹត្តអំពើសុចរិត ព្រះអង្គមុខជាគាប់ព្រះហឫទ័យនឹងអ្នកនោះមិនខាន។ កក ១០,៣៥

**ដំណឹងល្អ៖ ម៉ាថាយ ៣,១៣-១៧**

លោកយ៉ូហានប្រកែកថា៖ ខ្ញុំទេតើដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្ដេចក៏លោកមករកខ្ញុំវិញ!។ មថ ៣,១៤

បងប្អូនជាទីស្រឡាញ់!

យើងស្ដាប់ពីការត្រាស់ហៅរបស់បងស្រីសានីអម្បាញ់មិញ ដែលបងស្រីប្រធានបានត្រាស់ហៅយ៉ាងឱឡារឹក ដើម្បីចូលទៅក្នុងពាក្យសច្ចានិរន្ដរ៍ (អស់មួយជីវិត) នៅក្នុងក្រុមគ្រួសារបងស្រីឧបការគុណ។ ថ្ងៃនេះ យើងគោរពបុណ្យព្រះយេស៊ូដែលទទួលពិធីជ្រមុជទឹក ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់។ ប៉ុន្មានថ្ងៃមុន យើងបានចូលនៅក្នុងពិធីបុណ្យព្រះយេស៊ូប្រសូតចាប់កំណើតជាមនុស្ស យើងនឹកឃើញដល់ព្រះនាងម៉ារី ដែលទទួលដំណឹងពីទេវទូតកាព្រីអែល នឹកឃើញដល់ព្រះយេស៊ូដែលបានប្រសូតនៅភូមិបេថ្លេហិម នឹកឃើញដល់ព្រះយេស៊ូដែលបង្ហាញឋានៈរបស់ព្រះអង្គជាមួយហោរាចារ្យ។

ថ្ងៃនេះ ដែលព្រះយេស៊ូទទួលពិធីជ្រមុជទឹក យើងបានស្ដាប់យ៉ាងច្បាស់លាស់ព្រះជាម្ចាស់មានព្រះបន្ទូលថា "**ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់**"។ នៅពេលយើងមើលឃើញ ពីព្រះនាងម៉ារីទទួលដំណឹងពីទេវទូតកាព្រីអែល រហូតព្រះយេស៊ូទទួលពិធីជ្រមុជទឹក ដូចជាផ្លូវនៃជីវិតរបស់បងស្រីសានីដែរ។ បងស្រីសានី ដែលបានទទួលពិធីជ្រមុជទឹកនៅពេលដែលគាត់ធំហើយ គាត់មិនមែនជាគ្រីស្ដបរិស័ទពីកំណើត ដែលបានស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដែលបានចូលយ៉ាងជ្រៅដូចជាចាប់កំណើតនៅក្នុង

ព្រះសហគមន៍នៅក្នុងទឹកដីប្រទេសកម្ពុជា ដែលបានលាក់ខ្លួនមួយរយៈនៅក្នុងក្រុមគ្រួសារឧបការគុណ ជាពិសេសនៅពេលគាត់នៅជាណូវីស។ ក្រោយមកមានពាក្យសច្ចាដំបូង បានទៅរៀននៅប្រទេសបារាំងយូរឆ្នាំ ក្រោយមកបងស្រីត្រលប់មកវិញ។ ថ្ងៃនេះ ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ ដូចជាពិធីជ្រមុជទឹករបស់បងស្រីដែរដែលបានកើតជាថ្មី ដូចយើងបានស្ដាប់នៅក្នុងអត្ថបទទី២ "**កើតជាថ្មីដោយសារព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ឲ្យយើងបានទទួលជីវិតអស់កល្បជានិច្ច ជាមរតកដោយសេចក្ដីសង្ឃឹមរបស់យើង**"។ ខ្ញុំជឿថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "**នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង**" ថ្ងៃនេះព្រះជាម្ចាស់មានព្រះបន្ទូលថា "**នេះជាបុត្រីដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះនាងណាស់**"។

ថ្ងៃនេះ ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ រួមជាមួយទេវទូតដែលបានកោតសរសើរព្រះជាម្ចាស់ ក្នុងថ្ងៃដែលព្រះយេស៊ូប្រសូត រួមជាមួយក្រុមគ្រួសារបងស្រី។ ជាពិសេសថ្លែងអំណរគុណដល់ឪពុកម្ដាយរបស់បងស្រី គាត់មានកូន៥នាក់ មានពីរនាក់ដែលមានគ្រួសារហើយ និងយើងមានពីរនាក់ដែលពិសេសមែនទែនដោយសុខចិត្តផ្ញើជីវិតទៅលើព្រះជាម្ចាស់។ សារ៉ង នៅក្នុងក្រុមដុនបូស្កូ និងបងស្រីតេរេសា សានី នៅក្នុងក្រុមបងស្រីឧបការគុណ។ ប្រសិនបើ យើងពិចារណាលើការត្រាស់ហៅរបស់យើងនៅក្នុងទឹកដីប្រទេសកម្ពុជា គ្រួសារមួយចំនួនមិនមែនមានតែម្នាក់ដែលសុខចិត្តផ្ញើជីវិតប៉ុន្តែមានពីរនាក់ ហើយយើងមាន៣ទៅ៤គ្រួសាររបៀបហ្នឹង។

ដូច្នេះ នៅក្នុងក្រុមគ្រួសារយើងមានអ្វីពិសេស ដែលណែនាំឲ្យកូនអាចរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ ដូចពីដើមព្រះនាងម៉ារីដែលរស់នៅក្នុងគ្រួសារដ៏សុខសាន្ត និងណែនាំឲ្យព្រះនាងម៉ារីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អរគុណដល់បងស្រីឧបការគុណដែលបានធ្វើដំណើរជាមួយបងស្រី ដែលបានណែនាំដើម្បីបម្រើព្រះសហគមន៍នៅទីនេះ។ អរគុណដល់លោកឪពុកមួយចំនួនដែលបានធ្វើដំណើរជាមួយបងស្រី តាមផ្លូវវិញ្ញាណ តាមការអប់រំ តាមរយៈការបង្រៀន និងលើកទឹកចិត្តផងដែរ។ ដោយសារយើងមានមនុស្សមួយចំនួនដែលយកចិត្តទុកដាក់ដើម្បីធ្វើដំណើរជាមួយបងស្រីដែរ ដូច្នេះយើងអរព្រះគុណព្រះជាម្ចាស់។

ថ្ងៃនេះ ដូចជាសញ្ញារបស់ព្រះជាម្ចាស់ផ្ទាល់ដែលប្រទានទៅបងស្រី ទាំងព្រះបន្ទូលអត្ថបទទី១ ទី២ ទី៣ ដើម្បីណែនាំបងស្រីអស់មួយជីវិត ដោយព្រះជាម្ចាស់គង់នៅ។ អត្ថបទទី១គឺ ខ្ញុំសុំកែតិចៗដើម្បីឲ្យស៊ីនឹងបងស្រី "**បងស្រីជាអ្នកបម្រើដែលយើងគាំទ្រ បងស្រីជាអ្នកដែលយើងបានជ្រើសរើស និងជាអ្នកដែលគាប់ចិត្តរបស់យើង។ យើងបានដាក់ព្រះវិញ្ញាណរបស់យើងឲ្យសណ្ឋិតនៅលើបងស្រី បងស្រីមិនស្រែក ឬគំហកកំហែងដាក់នរណាឡើយ ហើយក៏មិនបន្លឺ**

**សំឡេងនៅតាមផ្លូវដែរ។ យើងបានហៅបងស្រីមកតាមសេចក្តីសុចរិតរបស់យើង។ យើងកាន់ដៃបងស្រី យើងទុកបងស្រីដោយដៃ ហើយតែងតាំងបងស្រីឲ្យចងសម្ព័ន្ធមេត្រីជាមួយប្រជាជន ឲ្យបងស្រីធ្វើជាពន្លឺបំភ្លឺប្រជាជាតិនានា ប្រោសមនុស្សខ្វាក់ឲ្យបានភ្លឺ នាំឈ្លើយចេញពីមន្ទីរឃុំឃាំង ព្រមទាំងរំដោះប្រជាជនដែលរស់នៅក្នុងភាពងងឹតឲ្យបានចេញរួចផុត"។** នេះជាគម្រោងការសម្រាប់បងស្រី គម្រោងការរបស់ព្រះជាម្ចាស់ដែលព្រះជាម្ចាស់បានរៀបចំអស់ហើយ ម្តងៗអានអត្ថបទនេះសាជាថ្មី ដើម្បីធ្វើដំណើរនៅក្នុងជីវិតផ្ទាល់ខ្លួន។

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលបងស្រីកំពុងបង្ហាញចំពោះព្រះសហគមន៍ ចំពោះព្រះជាម្ចាស់អស់មួយជីវិត។ សម្រាប់បងស្រីខ្ញុំមានចំណុចខ្លះៗ៖

**ទី១ បងស្រីជាអ្នកបម្រើដែលយើងជួយគាំទ្រ ជាអ្នកដែលយើងបានជ្រើសរើស និងជាអ្នកដែលបានគាប់ចិត្តយើង។** បន្តិចទៀត បងស្រីមានពាក្យសច្ចាមួយគឺ៖ រស់នៅតាមបង្គាប់បងស្រីប្រធានពិតមែន ប៉ុន្តែនៅក្នុងបង្គាប់នៃព្រះសហគមន៍ រួមជាមួយនឹងលោកអភិបាលដែរ។ ប៉ុន្មានថ្ងៃមុនខ្ញុំបានជួបជាមួយបព្វជិតបព្វជីតាដែលនៅភ្នំពេញ មានជាង២០ក្រុម ទាំងបងស្រី ទាំងបងប្រុសបានមកជួបជុំគ្នា យើងធ្វើដំណើរជាគ្រួសារតែមួយនៅភូមិភាគភ្នំពេញ និងក្នុងព្រះសហគមន៍កម្ពុជាទាំងមូល។ យើងមិនមែនរៀងៗខ្លួន យើងជាក្រុមបងស្រីមួយ ក្រុមលោកឪពុកមួយ យើងជាក្រុមដូនជីមួយ ហើយធ្វើដំណើរតាមផ្លូវដែលយើងចង់ទៅ ដោយគិតថាព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើងតែប៉ុណ្ណឹង។ តែនៅក្នុងព្រះសហគមន៍ទាំងមូល រួមជាមួយលោកអភិបាល រួមជាមួយក្រុមបងស្រីនីមួយៗ រួមជាមួយបងប្អូនម្នាក់ៗយកពេលធ្វើដំណើរជាមួយគ្នាដោយដឹងថាព្រះជាម្ចាស់បានជ្រើសរើសយើង។ ឆ្នាំនេះ យើងប្រារព្ធ៣០ឆ្នាំដែលព្រះសហគមន៍កាតូលិកកម្ពុជាបានរស់ឡើងវិញ ៣០ឆ្នាំដែលលោកអេមីល និងលោកអភិបាលអ៊ីវ បានថ្វាយអភិបូជាសាជាថ្មីនៅចេនឡា ថ្ងៃទី១៤ ខែមេសា ក្នុងឆ្នាំ១៩៩០។ ៣០ឆ្នាំដែលព្រះសហគមន៍បានចាប់ផ្តើមបន្តិចម្តងៗ យើងមានគ្រីស្តបរិស័ទដែលបានតស៊ូ ដោយមានគ្រីស្តបរិស័ទដែលបានធ្វើដំណើរទោះបីជាមានពេលវេលាដ៏ពិបាកនៅក្នុងប្រទេសយើង ក៏ប៉ុន្តែបានតស៊ូដើម្បីថែទាំ ថែរក្សាជំនឿផ្ទាល់ខ្លួន។ ថ្ងៃនេះ ជាពេលវេលាសម្រាប់បងស្រីផ្ទាល់ និងសម្រាប់យើងជាគ្រីស្តបរិស័ទទាំងអស់ ដើម្បីបន្តសរសេរប្រវត្តិសាស្ត្រដ៏មានជីវិតនៃព្រះសហគមន៍របស់យើង ចាប់ពីពេលនេះតទៅ។ យើងស្តាប់បង្គាប់ពិតមែន យើងធ្វើតាមបងស្រីប្រធានពិតមែន ប៉ុន្តែនៅក្នុងការស្តាប់បង្គាប់ នៅក្នុងការបញ្ជា ឬការណែនាំបងស្រី ទោះបីជាយើងស្តាប់បង្គាប់ក៏ដោយ ក៏យើងត្រូវការបង្ហាញសេរីភាពរបស់យើង យើងត្រូវការបង្ហាញអំពីយោបល់របស់យើង អំពីគំនិតរបស់យើង យើងត្រូវការមានចិត្ត

ក្លាហាន ដើម្បីចូលទៅក្នុងគម្រោងការរបស់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អតទៅទៀត។ ត្រូវការសួរខ្លួនឯង **តើខ្ញុំចង់សរសេរអ្វីខ្លះនៅក្នុងសៀវភៅនៃជីវិតរបស់ព្រះជាម្ចាស់នៅលើទឹកដីប្រទេសកម្ពុជាតទៅទៀត?**

**ទី២** លោកមិនទន់ខ្សោយឡើយ លោកអង់អាចជានិច្ច នេះសម្រាប់បងស្រី "**បងស្រីមិនកាត់ផ្ដាច់ដើមត្រែងណាដែលទន់ហើយនោះទេ ហើយបងស្រីក៏មិនផ្លុំពន្លត់ភ្លើងណាដែលហៀបនឹងរលត់នោះដែរ**"។ មានន័យថានៅក្នុងពាក្យសច្ចាទី២ គឺសុខចិត្តលះបង់ចោល ដាក់ខ្លួនជាអ្នកក្រីក្រ យើងត្រូវតែធ្វើដំណើរជាមួយមនុស្សឯទៀតៗ ជាពិសេសមនុស្សតូចតាច។ យើងធ្វើដំណើរជាមួយគេ ឲ្យបងស្រីទៅជាព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់លើផែនដីនេះ មានន័យថាឲ្យបងស្រីទៅជាបេះដូងរបស់ព្រះជាម្ចាស់លើផែនដីនេះ។ ឧបការគុណ គឺព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ដែលកើតតាមរយៈជីវិតរបស់បងស្រីសម្រាប់បងប្អូនឯទៀតៗ។ នៅក្នុងជីវិតរបស់បងស្រី ត្រូវមើលផ្ទាល់ភ្នែកឧបការគុណរបស់ព្រះជាម្ចាស់ សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលយកអ្នកតូចតាច អ្នកក្រីក្រជាអាទិភាព។ ដោយសារបងស្រីសុខចិត្តលះបង់ចោល សុខចិត្តធ្វើជាអ្នកក្រីក្រ ក៏ប៉ុន្តែនៅក្នុងចិត្តបងស្រី សុខចិត្តលះបង់ចោលអ្វីៗទាំងអស់កុំឲ្យភ្ជាប់ជាមួយអ្វីសោះ ដើម្បីចូលជាផ្លូងតែមួយជាមួយបងប្អូនឯទៀតៗ ដើម្បីបង្ហាញសេចក្ដីស្រឡាញ់។ ខ្ញុំអធិដ្ឋានសម្រាប់បងស្រីរកឃើញផ្លូវថ្មី ដើម្បីប្រកាសដំណឹងល្អដល់បងប្អូនតូចតាចដែលទន្ទឹងរង់ចាំ។ ប៉ុន្មានថ្ងៃមុន ខ្ញុំបានទៅកែបជាមួយអ្នកភូមិសុខសាន្ត យើងឃើញក្មេងពិការយ៉ាងធ្ងន់មែនទែន នៅពេលគេចូលទៅក្នុងទឹកសមុទ្រជាមួយឪពុក ជាមួយម្ដាយ ជាមួយបងប្អូនគេ ដែលលើកគេចេញពីកៅអីដើម្បីចូលទៅក្នុងទឹកសមុទ្រ នៅពេលនោះយើងឃើញស្នាមញញឹមរបស់គេ ដោយសារគេមានអារម្មណ៍ថាគេអាចដើរបាន គេអាចរត់បាន ដូចជាខ្លួនគេចេញពីជញ្ជាំងដែលមាននៅលើផែនដីនេះ។ នៅពេលយើងឃើញបងប្អូនដែលញញឹមរបៀបនេះ យល់ថាពិតមែនព្រះជាម្ចាស់ត្រាស់ហៅយើង ឲ្យយើងធ្វើដំណើរជាមួយអ្នកតូចតាចដើម្បីឲ្យគេមើលឃើញផ្ទាល់ភ្នែកនូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

**ទី៣ ឲ្យបងស្រីចងសម្ព័ន្ធមេត្រីជាមួយប្រជាជន ឲ្យបងស្រីធ្វើជាពន្លឺបំភ្លឺដល់ប្រជាជាតិនានា ប្រោសមនុស្សខ្វាក់ឲ្យបានភ្លឺ នាំមនុស្សឈ្លើយចេញពីកន្លែងឃុំឃាំង ព្រមទាំងរំដោះប្រជាជនដែលរស់នៅក្នុងភាពងងឹត**។ នេះជាមហាកំពូលនៃបេសកកម្ម បងស្រីអាចធ្វើបានដោយសារបងស្រីសុខចិត្តធ្វើជីវិតទាំងស្រុង ព្រហ្មចារិនីនៅក្នុងការបម្រើព្រះសហគមន៍ អត់មានប្ដី អត់មានគ្រួសារមួយផ្ទាល់ ប៉ុន្តែបងប្អូនទាំងអស់ទៅជាក្រុមគ្រួសារមួយយ៉ាងពិសេស។ មិនមែនតែគ្រីស្ដបរិស័ទ

ប៉ុន្តែប្រជាជាតិទាំងឡាយ យើងមិននឹកឃើញដល់១៥,០០០នាក់ដែលជាគ្រីស្តបរិស័ទនៅភូមិភាគភ្នំពេញ និង២០,០០០នៅទូទាំងប្រទេស យើងគិតដល់១៦,០០០,០០០នាក់ដែលជាបងប្អូនបង្កើតរបស់យើងនៅលើទឹកដីកម្ពុជា ដើម្បីណែនាំឲ្យគេរកឃើញពន្លឺនៅក្នុងជីវិត សេចក្តីសង្ឃឹមនៅក្នុងជីវិត។ ខ្ញុំចង់និយាយទៅបងស្រីថា សូមបើកទ្វារនៃដួងចិត្ត ហើយសូមចេញពីអារាម សូមចេញពីវិហារ ដើម្បីមើលឃើញ **តើមានអ្វីខ្លះនៅលើទឹកដីរបស់យើង?** ចេញទៅដើម្បីមើលកូនក្មេងមានច្រើនណាស់ដែលកំពុងទន្ទឹងរង់ចាំសេចក្តីស្រឡាញ់។ ឲ្យបងស្រីបើកទ្វារដើម្បីណែនាំឲ្យមនុស្សជាប់ឃុំឃាំងរកឃើញសេរីភាពសាជាថ្មី ទោះបីគេរស់នៅក្នុងមន្ទីរឃុំឃាំង ប៉ុន្តែគេអាចរកឃើញសេរីភាពនៅក្នុងដួងចិត្ត។ ពេលយើងមើលខ្លែងឯកឡើងខ្ពស់មែនទែន ប៉ុន្តែជាប់វានឹងខ្សែ ហើយខ្សែនេះជាព្រំដែនដែលណែនាំឲ្យសេរីភាពរបស់យើងទៅមុខ។ បងស្រីមានខ្សែជា ធម្មវិន័យ ពាក្យសច្ចាទាំងបីជាខ្សែសំខាន់ណាស់ ប្រសិនបើកាត់ខ្សែនេះ ខ្លែងមិនដឹងទៅណាទៅណី។ យើងមានព្រះសហគមន៍ យើងមានគ្រីស្តបរិស័ទ យើងមានបងប្រុសបងស្រី យើងមានបងប្អូន យើងមានពាក្យសច្ចា យើងមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជាខ្សែយ៉ាងពិសេសដើម្បីណែនាំឲ្យបងស្រីទៅមុខនៅក្នុងសេរីភាព ប៉ុន្តែសេរីភាពដែលយើងទទួលពីព្រះជាម្ចាស់។

យើងអធិដ្ឋានទូលអង្វរដល់ព្រះជាម្ចាស់ សម្រាប់បងស្រីម៉ារីអាឌែល យើងអធិដ្ឋានទូលអង្វរដល់ព្រះជាម្ចាស់សម្រាប់បងស្រីឧបការគុណ យើងអធិដ្ឋានសម្រាប់ព្រះសហគមន៍យើងទាំងអស់ ដល់បព្វជិតបព្វជិតា និងជាពិសេសយើងអធិដ្ឋានសម្រាប់យុវនារីឲ្យបើកភ្នែក បើកដួងចិត្ត បើកត្រចៀក និងថ្ងៃណាមួយឲ្យមានយុវនារីទៅជាផ្លែមួយយ៉ាងស្អាត នៅក្នុងព្រះសហគមន៍ដើម្បីប្រកាសដំណឹងល្អ នៅក្នុងភូមិភាគភ្នំពេញ បាត់ដំបង និងកំពង់ចាម ដើម្បីឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់ នៅក្នុងសេចក្តីសុខ នៅក្នុងអំណរសប្បាយរបស់ព្រះជាម្ចាស់ និងអរព្រះគុណព្រះអង្គ។ អាម៉ែន៕